# សាលារៀនជំនាន់ថ្មី




## ការជួយយុវជនឲ្យត្រៀម លក្ខណៈសម្រាប់សតវត្សទី២១

## ការលើកកម្ពស់គណនេយ្យភាព

សាលារៀនជំនាន់ថ្មីនីមួយៗនឹងត្រូវត្រួតពិនិត្យ និងវាយតម្លៃដោយក្រុមប្រឹក្សាភិបាលដែលតម្រូវឱ្យមានបំពេញភារកិច្ចប្រកបដោយស្តង់ដារខ្ពស់។

# ទិដ្ឋភាពទូទៅ

កម្មវិធីសាលារៀនជំនាន់ថ្មីគឺជាធាតុដ៏សំខាន់មួយនៃកម្មវិធីកំណែទម្រង់វិស័យអប់រំដែលបានផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា។ គំនិតផ្តួចផ្តើមនេះឈានទៅបង្កើតគំរូអភិវឌ្ឍមួយដែលនឹងនាំទៅរកការបង្កើតសាលារៀនរដ្ឋស្វយ័ត ដែលនឹងទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់ទៅនឹងស្តង់ដារថ្មីមួយនៃគណនេយ្យភាព  និងអភិបាលកិច្ចល្អ។ សាលាដែលមិនឆ្លើយតបនឹងស្តង់ដារជាសាលារៀនជំនាន់ថ្មីនឹងបាត់បង់ឋានៈជាសាលារៀនជំនាន់ថ្មី ជាលំនាំមួយខុសពីការវិនិយោគលើវិស័យអប់រំ ដែលក្រសួងធ្លាប់អនុវត្តកន្លងមក។ សាលារៀនជំនាន់ថ្មីនឹងផ្តល់ស្តង់ដារអប់រំថ្មីមួយនៅក្នុងសាលារដ្ឋដើម្បីឲ្យយុវជនកម្ពុជារៀបចំត្រៀមខ្លួនសម្រាប់សតវត្សទី២១។

កម្មវិធីនេះនឹងចាប់ផ្តើមនៅវិទ្យាល័យ **ព្រះស៊ីសុវត្ថិ** រាជធានីភ្នំពេញ។ ផ្អែកលើការសាកល្បងគំរូដើមដោយជោគជ័យនៅសាលាអនុវត្ត ខេត្តកំពង់ចាម គម្រោងនេះទទួលមូលនិធិផ្ទាល់ពី **ក្រសួងអប់រំ យុវជន និងកីឡា** ដោយសហការប្រតិបត្តិដោយ **អង្គការសម្ព័ន្ធភាពសម្រាប់បឋមសិក្សានៅកម្ពុជា “ខេប”**។



# សាលារៀនជំនាន់ថ្មី



# វិធីសាស្ត្រ

កម្មវិធីសាលារៀនជំនាន់ថ្មីនឹងផ្តោតលើការបង្រៀនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាផ្នែកសំខាន់។ ជំនាញទាំងនេះគឺជាជំនាញដែលយុវជនកម្ពុជាត្រូវការចាំបាច់នៅពេលកម្ពុជាបានចូលសមាហរណកម្មអាស៊ាន។ ដូច្នេះ សាលារៀនជំនាន់ថ្មីនឹងបន្ថែមម៉ោងបង្រៀនសម្រាប់មុខវិជ្ជាដូចខាងក្រោម៖ គីមីវិទ្យា រូបវិទ្យា ជីវះវិទ្យា និងបច្ចេកវិទ្យាព័ត៌មាន។

កម្មវិធីនឹងទទួលបានការវិនិយោគពិសេស ដើម្បីធ្វើទំនើបកម្មសម្ភារៈសិក្សានៅសាលារៀន រួមមានការជួសជុលបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ ទំនើបកម្មថ្នាក់រៀន បណ្ណាល័យសតវត្សទី២១ និងការិយាល័យប្រឹក្សាដល់សិស្សានុសិស្ស។

# ការអភិវឌ្ឍវិជ្ជាជីវៈ គ្រូបង្រៀន



ការជ្រើសរើសគ្រូបង្រៀនត្រូវធ្វើឡើងតាមការប្រកួតប្រជែងសមត្ថភាព ដើម្បីឲ្យបានគ្រូល្អៗបង្រៀននៅសាលារៀននេះ។ គ្រូបង្រៀនទទួលបានការជួយជ្រោមជ្រែងអភិវឌ្ឍន៍ស្តង់ដារវិជ្ជាជីវៈខ្ពស់រាប់ទាំងការលុបបំបាត់ការទម្លាប់បង្រៀនគួ។ គ្រូ និងគណៈគ្រប់គ្រងដែលបានជ្រើសរើសនៅវិទ្យាល័យហ៊ុន សែន កំពង់ចាមត្រូវចូលរួមក្នុងកម្មវិធីបំប៉នសមត្ថភាពបន្តបន្ទាប់ ដោយចាប់ផ្តើមពីវគ្គបំប៉នមូលដ្ឋានគ្រឹះ និងវគ្គបំប៉នបន្តពេញមួយឆ្នាំ និងសិក្ខាសាលាឆ្លុះបញ្ចាំងពិសេស។ គណៈគ្រប់គ្រងសាលានឹងទទួលការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ការធ្វើផែនការ គោលការណ៍នៃការពង្រឹងសិទ្ធិអំណាចយុវជន និងការអនុវត្តម៉ឹងម៉ាត់តាមគោលការណ៍របស់ក្រសួងស្តីពីអភិបាលកិច្ចល្អសាលារៀន។


**ទំនាក់ទំនង**

**វិទ្យាល័យ ហ៊ុន សែន កំពង់ចាម**

ផ្លូវជាតិលេខ៧ ភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

ទូរសព្ទលេខ: ០៩៧ ៩៧ ០០ ២២៤ / ០១០ ២៩០ ២២៤

គេហទំព័រ: **www.kapekh.org** ទំព័របណ្តាញសង្គម:

**www.facebook.com/kapeaction or .../ngsaction**






# សាលារៀនសម្រាប់មនុស្សជំនាន់ថ្មី...

## សេវាពង្រឹងសិទ្ធិអំណាចយុវជន

គោលការណ៍ពង្រឹងសិទ្ធិអំណាចយុវជន គឺស្របតាមគោលនយោបាយអភិវឌ្ឍយុវជនកម្ពុជារបស់ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីសំខាន់ក្នុងសាលារៀនជំនាន់ថ្មី។ គោលការណ៍ពង្រឹងសិទ្ធិអំណាចយុវជនស្តែងចេញតាមរយៈជម្រើសរបស់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាដែលគេចូលចិត្ត ការស្ម័គ្រចិត្តចូលរួមក្នុងក្លឹបសិក្សា និងការផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាកុមារ/យុវជនដែលនឹងជួយគ្រប់គ្រងកម្មវិធី។ សេវាប្រឹក្សាអាជីពដែលផ្តល់ដល់យុវជននឹងជួយគេដើម្បីធានាថាគេសម្រេចចិត្តត្រឹមត្រូវ ឆ្លាតវៃ និងមានព័ត៌មានគ្រប់គ្រាន់។

## សេវាពិសេសដល់សិស្ស

សាលារៀនជំនាន់ថ្មីនឹងផ្តល់នូវសេវាថ្មីមួយដែលមិនធ្លាប់មានក្នុងសាលារៀនរដ្ឋធម្មតា រួមមាន៖

*បណ្ណាល័យអេឡិចត្រូនិកសតវត្សទី ២១ សេវាប្រឹក្សា ក្លឹបមុខវិជ្ជា ការអប់រំបំណិនជីវិត ការវាយតម្លៃ និងរៀនតាមកម្មវិធីកុំព្យូទ័រ និងអេឡិចត្រូនិច។*